**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៨៣៣ ព.ណ.ជ.ស.រ

ថ្ងៃ ពុធ ១២ កើត ខែ ពិសាខ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សាអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣១ ខែឧសភា ឆ្នាំ២០១៩ នឹងត្រូវលក់ ៣.៩៦៧រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៨៤៥រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី១៦ ដល់៣១ ខែឧសភា ឆ្នាំ២០១៩** នឹងចុះមក ៣.៨០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៦៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,៤៧៤៣ដុល្លារ | ០,៥២៣៦ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៧៩១ ដុល្លារ | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | ០,០២៩៦ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៨៥៣ ដុល្លារ | ០,០៨២៣ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩៣៨៨ ដុល្លារ | ០,៩០៥៥ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៨០៥ រៀល | ៣.៦៧០ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩៤ ដុល្លារ | ០,៩១ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៨០០ រៀល | ៣.៦៥០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៦ខែឧសភា ឆ្នាំ២០១៩ ដែលស្មើនឹង ៤០៥៣រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង DO 0.05% (USD/Barrel) |
|---|---|---|
| ២ ឧសភា ២០១៩ | ៧៨,៦៤ | ៨៣,៨០ |
| ៣ ឧសភា ២០១៩ | ៧៧,១៥ | ៨៣,២៧ |
| ៦ ឧសភា ២០១៩ | ៧៥,៧៨ | ៨២,៨៩ |
| ៧ ឧសភា ២០១៩ | ៧៥,៥០ | ៨៣,៧៦ |
| ៨ ឧសភា ២០១៩ | ៧២,៦៤ | ៨២,៤២ |
| ៩ ឧសភា ២០១៩ | ៧២,៦២ | ៨២,៤៦ |
| ១០ ឧសភា ២០១៩ | ៧៥,៤១ | ៨៣,១៨ |
| ១៣ ឧសភា ២០១៩ | ៧៦,៥២ | ៨៤,៤៤ |
| ១៤ ឧសភា ២០១៩ | ៧៤,៧០ | ៨២,៦១ |
| ១៥ ឧសភា ២០១៩ | ៧៥,២៧ | ៨៣,៨២ |
| **មធ្យមភាគ ១០ថ្ងៃ** | **៧៥,៤២១០** | **៨៣,២៤៥០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៤៧៤៣** | **០,៥២៣៦** |

## ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ខែ កុម្ភៈ ដល់ ១៦ ខែ មេសា ឆ្នាំ២០១៩




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។